# Help Me Grow Maine

## តើកម្មវិធី Help Me Grow អាចជ្រោមជ្រែងអ្នក និងការអនុវត្តរបស់អ្នកដោយរបៀបណា?

ក្នុងនាមជាអ្នកមានវិជ្ជាជីវៈផ្នែកថែទាំសុខភាព គឺអ្នកយល់ពីសារៈសំខាន់ខ្លាំងនៃការរកឃើញបញ្ហា និងធ្វើអន្តរាគមន៍ពេលកុមារនៅតូចចំពោះអ្នកជំងឺរបស់អ្នក ។Help Me Grow ជួយជ្រោមជ្រែងអ្នកក្នុងការថែទាំអ្នក ជំងឺរបស់អ្នក ដោយការផ្តល់ជូននូវសេវាខាងក្រោម៖



- ពិនិត្យការអភិវឌ្ឍន៍រាងកាយ និងខួរក្បាលអ្នកជំងឺដោយឥតគិតថ្លៃ តាមរយៈការប្រើបញ្ជីកម្រងសំណួរអំពីអាយុ និងដំណាក់កាលនៃការលូតលាស់ (Ages & Stages Questionnaires®)
- គន្លឹះចំពោះការធ្វើជាឪពុកម្តាយគេ, សកម្មភាព និងព័ត៌មានសំខាន់ៗ
- ការចាត់បញ្ជូន ការផ្សារភ្ជាប់ជាមួយនឹងធនធានដែលមាននៅក្នុងសហគមន៍
- តាមដានជាមួយគ្រួសារអ្នកជំងឺ ដើម្បីធានាថាកុមារទទួលបានសេវាដែលពួកគេត្រូវការ
- ចែករំលែកលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលលើការថែទាំកុមារ របស់យើងខ្ញុំ ដើម្បីពង្រឹងទំនាក់ទំនងរវាងអ្នក និងអ្នកជំងឺរបស់អ្នក

## តើ Help Me Grow Maine មានដំណើរការរបៀបណា?

1. អ្នកផ្តល់សេវាបញ្ជូនគ្រួសារអ្នកជំងឺមកកាន់ HMG Maine ។
2. HMG ផ្តល់ជូនព័ត៌មានអំពីការលូតលាស់របស់កុមារ និងផ្តល់ជូនការពិនិត្យមើលអំពីការលូតលាស់របស់កុមារ ។
3. HMG បញ្ជូនគ្រួសារអ្នកជំងឺទៅកាន់សេវាការអភិវឌ្ឍន៍កុមារប្រចាំមូលដ្ឋាន និងសេវាគ្រប់ជ្រុងជ្រោយ ។
4. HMG ជួយតាមដានគ្រួសារអ្នកជំងឺ ដើម្បីធានាបាននូវភាពជោគជ័យ ចំពោះការតភ្ជាប់ជាមួយនឹងសេវា និងផ្តល់ជូនការពិនិត្យបន្ថែម ។
5. បើចាំបាច់ HMG នឹងធ្វើការបញ្ជូនអ្នកជំងឺទៅកាន់កន្លែងផ្សេងទៀត ។

## តើអ្នកមានបានដឹងទេ?

91% នៃកុមារនៅក្នុងរដ្ឋមេន បានទទួលសេវាវេជ្ជសាស្ត្រ ដើម្បីបង្ការជំងឺនានា កាលពីឆ្នាំកន្លងទៅ ដែលនេះជាតួលេខខ្ពស់ជាងតួលេខជាមធ្យមរបស់ថ្នាក់ជាតិ គឺ 82% ។

កុមារ 2 ក្នុងចំណោមកុមារ 3 នាក់ នៅក្នុងរដ្ឋមេន អាយុពី 9 ខែ ដល់ 3 ឆ្នាំ នៅមិនទាន់បានទទួលការពិនិត្យមើលការលូតលាស់របស់ពួកគេឡើយ ។

ស្ទើរតែ 1 ក្នុងចំណោមកុមារ 4នាក់នៅក្នុងរដ្ឋមេន មានតម្រូវការពិសេសផ្នែកការថែទាំសុខភាព ។

Department of Health and Human Services, Maine

211 Maine | លេខទូរស័ព្ទផ្នែករដ្ឋបាល ៖ 1-833-714-7969 | HelpMeGrow@maine.gov

https://www.maine.gov/dhhs/ocfs/support-for-families/child-development

Help Me Grow
Maine

# តើរបៀបមើលថៃកុមាររបស់អ្នក អាចជួយលើកកម្ពស់ការត្រួតពិនិត្យ និងការឃ្លាំមើលអំពីការលូតលាស់របស់កុមារដែរឬទេ?

រៀនមើលអំពីសញ្ញានៃបញ្ហា ។ ចាត់សកម្មភាពឲ្យបានលឿន ។
បញ្ជីគោលសំខាន់ធ្វើឲ្យការឃ្លាំមើលការលូតលាស់របស់កុមារ មានភាពងាយស្រួល ៖

- យោងតាមគោលសំខាន់របស់សមាគមន៍ពេទ្យកុមារអាមេរិកាំង (American Academy of Pediatrics (AAP))
- ជួយអ្នកឲ្យចេះធ្វើការឃ្លាំមើលអំពីការលូតលាស់របស់កុមារជាប្រព័ន្ធ តាមអ្វីដែលជាអនុសាសន៍របស់ AAP
- ទំនាក់ទំនងជាមួយនឹងការពិនិត្យសុខភាពកុមារអាយុពី 2 ខែ ដល់ 5 ឆ្នាំ
- ត្រូវបំពេញដោយឪពុកម្តាយក្មេង ជួយពួកគេក្នុងការឆ្លើយតបបានកាន់តែត្រឹមត្រូវ ចំពោះការពិនិត្យមើលអំពីការលូតលាស់របស់កុមារ


Your baby at 6 months

Baby's Name | Baby's Age | Today's Date

Milestones matter! How your baby plays, learns, speaks, acts, and moves offers important clues about his or her development. Check the milestones your baby has reached by 6 months. Take this with you and talk with your baby's doctor at every well-child visit about the milestones your baby has reached and what to expect next.

What most babies do by this age:

Social/Emotional Milestones
- ☐ Knows familiar people
- ☐ Likes to look at himself in a mirror
- ☐ Laughs

Language/Communication Milestones
- ☐ Takes turns making sounds with you
- ☐ Blows "raspberries" (sticks tongue out and blows)
- ☐ Makes squealing noises

Cognitive Milestones (learning, thinking, problem-solving)
- ☐ Puts things in her mouth to explore them
- ☐ Reaches to grab a toy he wants
- ☐ Closes lips to show she doesn't want more food

Movement/Physical Development Milestones
- ☐ Rolls from tummy to back
- ☐ Pushes up with straight arms when on tummy
- ☐ Leans on hands to support himself when sitting

Other important things to share with the doctor...
- What are some things you and your baby do together?
- What are some things your baby likes to do?
- Is there anything your baby does or does not do that concerns you?
- Has your baby lost any skills he/she once had?
- Does your baby have any special healthcare needs or was he/she born prematurely?

You know your baby best. Don't wait. If your baby is not meeting one or more milestones, has lost skills he or she once had, or you have other concerns, act early. Talk with your baby's doctor, share your concerns, and ask about developmental screening. If you or the doctor are still concerned:

1. Ask for a referral to a specialist who can evaluate your baby more; and
2. Call your state or territory's early intervention program to find out if your baby can get services to help. Learn more and find the number at **cdc.gov/FindEI**.

For more on how to help your baby, visit **cdc.gov/Concerned**.

Act Early Maine
brought to you by Maine Developmental Disabilities Council
Don't wait.
Acting early can make a real difference!
Download CDC's free Milestone Tracker app
Help Me Grow Maine
2·1·1 Maine

# តើការអនុវត្តរបស់អ្នកមានផ្តល់ជូនការពិនិត្យអំពីការលូតលាស់របស់កុមារដែរឬទេ?

## មានផ្តល់ជូន!

Help Me Grow Maine អាចជួយអ្នកបានចំពោះ ៖

- ការជ្រោមជ្រែងតាមដានចំពោះគ្រួសារក្មេង
- ធ្វើបច្ចុប្បន្នភាពចំពោះសំណុំព័ត៌មានអំពីធនធាន ដើម្បីបញ្ជូនអ្នកជំងឺនិងតភ្ជាប់ជាមួយនឹងសេវាទាំងនោះ
- ជួយគ្រួសារកុមារក្នុងការចុះឈ្មោះទទួលសេវាពីកម្មវិធី
- ព័ត៌មានគន្លឹះអំពីការធ្វើជាឪពុកម្តាយគេ, សកម្មភាព និងព័ត៌មានផ្សេងៗទៀត ដែលមានសារៈសំខាន់
- ការបណ្តុះបណ្តាលបុគ្គលិកអំពីការលូតលាស់របស់កុមារត្រួតពិនិត្យ /ពិនិត្យមើល

## នៅឡើយទេ!

Help Me Grow Maine អាចជួយអ្នកបានគ្រប់រឿងដូចបានរៀបរាប់រួចមកហើយ បូករួមទាំង ៖

- រៀបចំដំណើរការពិនិត្យជាផ្លូវការ ចំពោះសកម្មភាពមើលថៃក្មេង

# តើអ្នកអាចភ្ជាប់អ្នកជំងឺរបស់អ្នកជាមួយនឹង Help Me Grow Maine ដោយរបៀបណា?

ណែនាំគ្រួសារអ្នកជំងឺឲ្យហៅទូរស័ព្ទទៅលេខ 211 / Help Me grow ក្នុងអំឡុងពេល ឬក្រោយពេលមកពិនិត្យសុខុមាលភាពកុមារ ។

ចាត់បញ្ជូនអ្នកជំងឺ ដោយការជួយបំពេញបែបបទសម្រាប់បញ្ជូន ដែលមាននៅក្នុងវិបសៃត៍របស់យើងខ្ញុំ ។

សូមហៅទូរស័ព្ទមកលេខ 211 និងស្នើសុំជួប Help Me Grow ។ បន្ទាប់មកបុគ្គលិកជំនាញធនធានរបស់យើងខ្ញុំ នឹងទាក់ទងជាមួយនឹងគ្រួសារអ្នកជំងឺ ។

នាយកដ្ឋានសេវាសុខភាព និងពលរដ្ឋ (DHHS) មិនមានការរើសអើងទេ ។

ព័ត៌មានយោង

- ព័ត៌មាន និងទ្រង់ទ្រាយនៃឯកសារនេះ នាំមកជូនអ្នកដោយ Help Me Grow Florida ។ មានការប្រែប្រួលតិចតួច ដើម្បីជ្រោមជ្រែងម៉ូដែលនៃ Help Me Grow Maine ។
- កញ្ចប់ថវិកា Title V នៃសេវាសុខភាពមាតា និងកុមារ ៖ការវាយតម្លៃតម្រូវការ និងសមត្ថភាពឆ្នាំ 2020 ដោយ CDC នៃនាយកដ្ឋានសេវាសុខភាព និងសេវាពលរដ្ឋប្រចាំរដ្ឋមែន ។